ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៨៩.០២.២០៥ ប្រ.ក

# ប្រកាស
## ស្តីពី
## ការកែប្រែមណ្ឌលសិក្សាបច្ចេកទេសធនាគារទៅជា
## វិទ្យាស្ថានបច្ចេកទេសធនាគារ

--------

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០២/០៣៩ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីការតែងតាំងឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ជាថ្មីម្តងទៀត
- បានឃើញប្រកាសលេខ ធ៨៩៨.៣៨៥ ប្រក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- បានឃើញប្រកាសលេខ ធ៨៩៩-១០២ ប្រក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ១៩៩៩ ស្តីពីរចនាសម្ព័ន្ធរបស់មណ្ឌលសិក្សាបច្ចេកទេសធនាគារ និង មុខងារ-ភារកិច្ចរបស់ការិយាល័យក្រោមឱវាទ
- យោងតាមភាពចាំបាច់និងសារៈសំខាន់នៃការបណ្តុះបណ្តាលវិស័យបច្ចេកទេសធនាគារ

## សំរេច

**ប្រការ ១ :** មណ្ឌលសិក្សាបច្ចេកទេសធនាគារ ដែលបច្ចុប្បន្នជាអង្គភាពមួយស្មើថ្នាក់នាយកដ្ឋានរបស់ធនាគារជាតិនៃកម្ពុជា មានអាស័យដ្ឋានលេខ១៩អាបេ ផ្លូវលេខ១០២ សង្កាត់វត្តភ្នំ

ខណ្ឌដូនពេញ ត្រូវបានកែប្រែឱ្យទៅជាបុគ្គលសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា ដែលមាន រូបភាពគតិយុត្តិជាក្រុមហ៊ុនមានលក្ខណៈពាណិជ្ជកម្ម និងធ្វើសកម្មភាពក្រោមច្បាប់និង បទប្បញ្ញត្តិនានាដែលពាក់ព័ន្ធដូចជា ច្បាប់ពាណិជ្ជកម្ម និង ច្បាប់ពាក់ព័ន្ធនឹងការសិក្សាអប់រំ ជាដើម ។

**ប្រការ ២ :** មណ្ឌលសិក្សាបច្ចេកទេសធនាគារត្រូវប្តូរឈ្មោះជាផ្លូវការទៅជា "**វិទ្យាស្ថានបច្ចេកទេសធនាគារ**" និងជាភាសាអង់គ្លេស "Institute for Banking Studies" ។

**ប្រការ ៣ :** វិទ្យាស្ថានបច្ចេកទេសធនាគារត្រូវមានលក្ខន្តិកៈដោយឡែក ដែលក្នុងនោះត្រូវមានចែង អំពីរូបភាពគតិយុត្ត ដើមទុន ទីតាំង កម្មវត្ថុនៃការសិក្សាអប់រំ ភារកិច្ចនិងការទទួលខុស ត្រូវរបស់ក្រុមប្រឹក្សាភិបាល នាយកចាត់ការ រចនាសម្ព័ន្ធរបស់វិទ្យាស្ថាន និងការងារដទៃ ទៀតដែលពាក់ព័ន្ធ ។

**ប្រការ ៤ :** ដើមទុនដំបូងរបស់វិទ្យាស្ថានបច្ចេកទេសធនាគារមានចំនួន ១.000.000.000 រៀល (មួយពាន់លានរៀល) ដែលផ្តល់ដោយធនាគារជាតិនៃកម្ពុជា ក្នុងនាមជាភាគទុនិក ១00 ភាគរយ ។ ដើមទុននេះនឹងត្រូវបង់ជា សាច់ប្រាក់និងជាសំភារៈតាមការជាក់ស្តែង ។

**ប្រការ ៥ :** វិទ្យាស្ថានបច្ចេកទេសធនាគារ ត្រូវធ្វើសកម្មភាពនិងមានការគ្រប់គ្រងដាច់ចេញពីធនាគារ ជាតិនៃកម្ពុជា នឹងត្រូវស្ថិតនៅក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាភិបាលរបស់វិទ្យាស្ថាន ។

**ប្រការ ៦ :** ក្រុមប្រឹក្សាភិបាលរបស់វិទ្យាស្ថានត្រូវបានតែងតាំងដោយធនាគារជាតិនៃកម្ពុជា និងមាន សមាជិកចំនួន ៥ រូប ។

**ប្រការ ៧ :** វិទ្យាស្ថានបច្ចេកទេសធនាគារត្រូវរៀបចំថវិកានិងផែនការហិរញ្ញប្បទាន ដើម្បីធានាឱ្យមាន កិច្ចដំណើរការជាប្រក្រតីនិងមាននិរន្តរភាព ជាអាទិ៍ការយកថ្លៃសិក្សាតាមកំរិតមួយសម ស្របដែលអាចធ្វើឱ្យមានតុល្យភាពរវាងចំណូលនិងចំណាយ ។

**ប្រការ ៨ :** កម្មវត្ថុចំបងនៃវិទ្យាស្ថានបច្ចេកទេសធនាគារ គឺផ្តល់សេវាអប់រំអំពីការងារធនាគារនិងបញ្ហា ពាក់ព័ន្ធដទៃទៀត ដើម្បីលើកកំពស់ចំណេះដឹងជំនាញបច្ចេកទេសធនាគារចំពោះមន្ត្រីបុគ្គលិក

ធនាគារជាតិនៃកម្ពុជា និងចំពោះសាធារណជន ។

**ប្រការ ៩ :** អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន-អង្គភាព ក្រោមឱវាទធនាគារជាតិនៃកម្ពុជាដែលមានការពាក់ព័ន្ធ និងវិទ្យាស្ថានបច្ចេកទេសធនាគារ ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ១០ :** រាល់ប្រកាស ឬលិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ១១ :** ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ខែតុ៧ ឆ្នាំ ២០០២

**ទេសាភិបាល**

**ជា ចាន់តូ**

**កន្លែងទទួល :**

- ដូចប្រការ ៩
  " ដើម្បីអនុវត្ត "
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីជូនជ្រាបជាពត៌មាន "
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីចុះផ្សាយក្នុងរាជកិច្ច "